# អ្នកស្នេហាជាតិប្រតិកម្មនឹងការគំរាមរបស់ហ៊ុន សែន



លោកថាច់ សេដ្ឋា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោម

**ដោយៈ គ.និមល**

លោកហ៊ុន សែន ដែលបាននិយាយថា និងជួយទិញក្តារមឈូសជូនអ្នកដែលចង់បានទឹកដីខ្មែរកម្ពុជាក្រោមមកវិញនោះ ជាការឆ្លើយតបដើម្បីគេចវេះពីទំនួលខុសត្រូវទូវបូរណភាពទឹកដី. នេះជាការអះអាងរបស់មន្ត្រីអង្គការខ្មែរកម្ពុជាក្រោមនិងមន្ត្រីគណបក្សនយោបាយមួយចំនួន ដោយបន្ថែមថា ទឹកដីខ្មែរកម្ពុជាក្រោមនៅតែជារបស់ខ្មែរដដែល ។

អង្គការក្រៅរដ្ឋាភិបាលនិងមន្ត្រីគណបក្សប្រឆាំងថ្លែងថាការឆ្លើយរបស់ប្រមុខរដ្ឋាភិបាលកម្ពុជា លោកហ៊ុន សែនដែលថា អ្នកណាចង់បានទឹកដីខ្មែរកម្ពុជាក្រោមមក

តនៅទំព័រទី ២ ២

នរោត្តម រណឫទ្ធិផង នៅតែសម្តេចក្រុមព្រះ អោយលោកយូហុកត្រី និងលោកស៊ុត ឌីណាប្រមាថ. ចុះសមាជិកចម្ងួតានិងប្រជាពលរដ្ឋវិញ តើព្រះអង្គមើលងាយយ៉ាងណា។ដូច្នេះហើយបានជាថ្នាក់ដឹកនាំ គណបក្សនរោត្តម រណឫទ្ធិ ចាត់ទុកប្រជាពលរដ្ឋជាដី និងជាអ្នកដែលខ្លួនងាយបោកប្រាស់ ។

ទទឹមនឹងព្រះអង្គម្ចាស់អង្គុយឈិមសូហ៊្វីនលាលែងនេះដែរ ប្រធានគណបក្សនរោត្តម រណឫទ្ធិ ឃុំបោយប៉ែតលោកកែវ សំអាត ហៅសម សុវណ្ណារ៉ា និងជាជំទប់ទី២ឃុំផងនោះ បាននាំសមាជិកគណបក្សនរោត្តម រណឫទ្ធិ ជាង ១.០០០នាក់ចូលរួមជាមួយគណបក្សហ៊្វុនស៊ិនប៉ិច និងបានទម្លាក់ស្លាកគណបក្សនរោត្តម រណឫទ្ធិ ហើយលើកស្លាក គណបក្សហ៊្វុនស៊ិនប៉ិចជំនួសវិញដែរ ៕

តមកពីទំព័រទី ១៥

វិញ។ លោកនឹងទិញក្តារមឈូសជូននោះ ជាការបញ្ជោះបញ្ជោកអ្នកដែលមានបំណងចង់បានទឹកដីនេះមកវិញ ។ ការឆ្លើយរបស់ប្រមុខរដ្ឋាភិបាលកម្ពុជានេះ ធ្វើឱ្យដូនតាខ្មែរដែលស្លាប់ព្រោះបុព្វហេតុជាតិមាតុភូមិនិងសាសនានឹងមិនសូប់ចិត្តទេ។

លោករ៉ុង ឈុន ប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យដែលធ្លាប់តែរិះគន់បញ្ហាព្រំដែននៅប្រទេសកម្ពុជានិងធ្លាប់បានរដ្ឋាភិបាលកម្ពុជាចាប់ដាក់ពន្ធនាគារព្រៃសកាលពីឆ្នាំ២០០៥បានបញ្ចេញជំហរដែលថាទឹកដីខ្មែរមួយចំនួនស្ថិតក្នុងខេត្តកំពង់ចាម ស្វាយរៀង កណ្តាល និងខេត្តកំពតនៅតែបាត់បង់ទៅយួនទៅឡើយ។ប្រទេសវៀតណាមបានរំកិលចូលជាបន្តបន្ទាប់។

លោកបញ្ជាក់ថា សង្គមស៊ីវិលនិងប្រជាពលរដ្ឋទូទៅ នៅតែកង្វល់ពីបញ្ហាបូរណភាពទឹកដីនេះ។ លោករ៉ុង ឈុននិយាយថា "តាមការពិត អ្វី១ដែលខ្ញុំធ្លាប់ទាមទារ ក៏ដូចជាការថ្លែងការណ៍ពាក់ព័ន្ធនឹងបញ្ហាបូរណភាពទឹកដីហ្នឹង អត់មានអ្វីប្រែប្រួលទេ ។ ប៉ុន្តែរាល់ការអះអាងរបស់ប្រមុខរដ្ឋាភិបាល បូរណភាពទឹកដីនៅកម្ពុជានៅតែបាត់ ។ គេយកទឹកដីខ្មែរដោយរំកិលបន្តិច១នៅតាមព្រំដែនខ្មែរយើង ។ យើងមើលឃើញតាមព្រំដែនកម្ពុជាយួនដូចជាខេត្តកំពង់ចាម ស្វាយរៀង តាកែវនិងកណ្តាលជាដើម ។ បញ្ហាទឹកដីវាជាប្រធានបទមួយសំខាន់និងជាចំណុចរសើបរបស់រដ្ឋាភិបាល។"

បញ្ហាទឹកដី បញ្ហាព្រំដែន ជាចំណុចក្តៅ និងជាចំណុចរសើបរបស់រដ្ឋាភិបាលកម្ពុជា ។ កន្លងមកមានការចាប់សកម្មជនព្រំដែនមួយចំនួនដែលបានរិះគន់រដ្ឋាភិបាលកម្ពុជាថាបាត់បង់ទឹកដីនោះដាក់ពន្ធនាគារ។

លោករ៉ុង ឈុនបន្តទៀតថាទឹកដីខ្មែរកម្ពុជាក្រោមដែលបាត់ទៅយើងត្រូវតែគិតគូរ.តែសំខាន់បំផុតយើងត្រូវតែរក្សាដីកម្ពុជាកណ្តាលឱ្យបានគង់វង់។

លោកថាច់ សេដ្ឋា ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមបានថ្លែងថា ការថ្លែងរបស់លោកនាយករដ្ឋមន្ត្រីហ៊ុន សែនដូច្នោះពិតជាបង្ហាញឱ្យឃើញនូវការមិនទទួលខុសត្រូវជាមេដឹកនាំទាល់តែសោះ ។ លោកថាច់ សេដ្ឋាបញ្ជាក់ថា ការយកទឹកដីកម្ពុជាក្រោមឬមិនយក វាមិនមែនជាកិច្ចការរបស់មនុស្សក្រុមណាមួយទេ ប៉ុន្តែជាកាតព្វកិច្ចរបស់រដ្ឋាភិបាល ។ ចំណែកអ្នកស្នេហាជាតិទាំងអស់ពុំមានអ្នកណាមិនចង់បានទឹកដីរបស់ខ្លួនដែលត្រូវបាត់បង់នោះមកវិញទេ ។ ដូច្នេះការថ្លែងរបស់លោកហ៊ុន សែនបែបនេះជាការប្រមាថមើលងាយអ្នកស្នេហាជាតិពេញទី។

ប្រធានសហគមន៍ខ្មែរកម្ពុជាក្រោមបានបន្តទៀតថា ចំពោះសហគមន៍ខ្មែរកម្ពុជាក្រោមមិនមែនតស៊ូ ដើម្បីទាមទារទឹកដីកម្ពុជាក្រោមទេ ប៉ុន្តែតស៊ូដើម្បីសិទ្ធិសេរីភាពរបស់ខ្មែរក្រោមដែលរស់នៅលើទឹកដីកំណើតរបស់ខ្លួនតែប៉ុណ្ណោះ ។លោកថាច់សេដ្ឋាបញ្ជាក់ថា ការថ្លែងបញ្ឈឺពោរពេញទៅដោយការប្រមាថជីវិតរបស់អ្នកស្នេហាជាតិពីសំណាក់លោកហ៊ុន សែនដូច្នេះ មិនសមជាអ្នកដឹកនាំទេ ហើយថាលោកហ៊ុន សែន គួរណាស់តែលើកទឹកចិត្តអ្នកស្នេហាជាតិ.មិនគួរបញ្ឈឺបន្ទុចបង្អាក់អ្នកស្នេហាជាតិតាមរយៈភាសាគឃ្លើនបែបនេះឡើយ ។

លោកអាង ចន្ទឫទ្ធិ នាយកប្រតិបត្តិអង្គការខ្មែរកម្ពុជាក្រោមការពារសិទ្ធិមនុស្ស បានមានប្រសាសន៍ថា ជំហររបស់ខ្មែរកម្ពុជាក្រោមទូទៅមិនទាន់ចង់ឱ្យរដ្ឋាភិបាលខ្មែរយកទឹកដីនោះមកវិញទេ គឺចង់ឱ្យតែរដ្ឋាភិបាលកម្ពុជាជួយអោយរដ្ឋាភិបាលវៀតណាមគោរពសិទ្ធិសេរីភាពសិទ្ធិសាសនារបស់ខ្មែរកម្ពុជាក្រោមឱ្យបានស្មើគ្នារវាងខ្មែរកម្ពុជាក្រោមនិងខ្មែរទូទៅតែប៉ុណ្ណោះ។

លោកបន្តថាចំពោះប្រសាសន៍របស់ប្រមុខរដ្ឋាភិបាលកម្ពុជាបែបនេះ គ្រាន់តែជាសម្តីមួយឆ្លើយឱ្យតែរួចផុតពីទំនួលខុសត្រូវរបស់រដ្ឋាភិបាលតែប៉ុណ្ណោះ ព្រោះទឹកដីខ្មែរកម្ពុជាក្រោមនៅតែជាទឹកដីរបស់ខ្មែរ។

លោកអាង ចន្ទឫទ្ធិនិយាយ ថា "ទាក់ទងនឹងប្រសាសន៍របស់លោក(ហ៊ុនសែន)និយាយថាបើអ្នកណាចង់បានទឹកដីខ្មែរកម្ពុជាក្រោមមកវិញ សូមជំរាបជូនថាគាត់នឹងត្រៀមក្តារមឈូសបញ្ជូនទៅឱ្យវិញនោះ វាគឺជារឿងមួយដែលខ្មែរកម្ពុជាក្រោមគិតថាជាការឆ្លើយឱ្យតែរួចផុតពីការទទួលខុសត្រូវរបស់រដ្ឋាភិបាល ។ដោយឡែក អ្វីដែលខ្មែរកម្ពុជាក្រោមគិតថាជារបស់ខ្លួននៅតែជារបស់ខ្លួនអីចឹង ព្រោះទឹកដីនេះជាទឹកដីរបស់ដូនតាខ្មែរយើងទាំងអស់គ្នា ។ អ្នកដឹកនាំរដ្ឋាភិបាល គួរណាស់តែជួយដោះស្រាយបញ្ហាអោយខ្មែរកម្ពុជាក្រោមទាំងអស់នោះបាននូវសិទ្ធិកាន់កាប់ទឹកដីនៅកន្លែងហ្នឹងដែលជាទឹកដីរបស់ពួកគាត់. ឱ្យគាត់ទទួលបាននូវសិទ្ធិកាន់កាប់ដីធ្លីគ្រប់គ្រាន់ដើម្បីប្រកបរបរចិញ្ចឹមជីវិតរស់នៅ" ។

លោកអេង នៃអ៊ាងអគ្គលេខាធិការគណបក្សសម រង្ស៊ី មានប្រសាសន៍ថា ខ្មែរកម្ពុជាក្រោមនៅតែរស់នៅក្នុងស្ថានភាពមួយដែលសិទ្ធិសេរីភាព និងជំនឿសាសនារបស់ពួកគាត់ ពុំទាន់ត្រូវបានគេគោរពនៅឡើយ ។

លោកអេង នៃអ៊ាងនិយាយថា "ខ្មែរក្រោមជាខ្មែរជនជាតិដើមត្រូវតែមានសេរីភាពពេញលេញដូចប្រជាពលរដ្ឋទូទៅហើយមានសិទ្ធិគោរពនូវប្រពៃណី សាសនាជំនឿរបស់ខ្លួន និងសិទ្ធិសេរីភាពរបស់មនុស្ស ដែលមានចែងនៅក្នុងសន្ធិសញ្ញាអន្តរជាតិ និងកតិកាសញ្ញាទាំងឡាយរបស់អន្តរជាតិ។"

គួរបញ្ជាក់ថា ម្សិលម៉្ងៃ លោកហ៊ុន សែននាយករដ្ឋមន្ត្រីខ្មែរបានមានប្រសាសន៍ថា អ្នកដែលមានបំណងចង់បានទឹកដីខ្មែរកម្ពុជាក្រោមមកវិញ. លោកសូមទិញក្តារមឈូសជូន។

លោកហ៊ុនសែននិយាយដូច្នេះថា "ដូនតាយើងទុកដីឱ្យយើងតែប៉ុណ្ណឹងទៅហើយ.យើងការពារអ្វីដែលវាមាន គឺមាននៅក្នុងរដ្ឋធម្មនុញ្ញប៉ុណ្ណឹងបានហើយ ។ខ្លះគេនិយាយថា ទៅយកកម្ពុជាក្រោម. សូមអញ្ជើញទៅ ។មានពេលណាមួយនោះ ខ្ញុំករុណាបាននិយាយថា ទៅយកខ្លួនឯងបាន ទៅយកទៅ! ទៅយកកម្ពុជាក្រោម សូមអញ្ជើញទៅ ។ ខ្ញុំករុណាខ្ញុំអត់មានលទ្ធភាពទេ ហើយសូមជួយទិញក្តារមឈូស ហើយជួយកប់សព ។ ទៅចូលស្រុកគេ១វាយមកវិញហើយចេះនិយាយអីចឹង! ស្នេហាជាតិអីតែឯងគេមិនស្នេហាជាតិ?"